Becoming secure, strong and independent

Family resources



# ទៅជាមានសុវត្ថិភាព រឹងមាំ និងឯករាជ្យ

## ធនធានសម្រាប់គ្រួសារ

ក្របខ័ណ្ឌការរៀនសូត្រសម្រាប់កុមារតូច (Early Years Learning Framework) គឺជាក្របខ័ណ្ឌជាតិលើការរៀនសូត្រ  ដែលត្រូវបានប្រើនៅក្នុងមត្តេយ្យសាលា និងសេវាកម្មកុមារតូចទាំងអស់។ វាណែនាំការបង្រៀន និងការរៀនសូត្រដោយមានលទ្ធផលនៃការរៀនសូត្រចំនួនប្រាំ ដែលជួយឱ្យកុមារក្លាយជាអ្នករៀនពូកែ និងមានសមត្ថភាព។

លទ្ធផលនៃការរៀនសូត្រទី 1 គឺអំពីកុមារមានការដឹងពីអត្តសញ្ញាណច្បាស់លាស់។ នេះជួយឱ្យកុមារមានទំនុកចិត្តថាពួកគេជានរណា និងអំពីវប្បធម៌របស់ពួកគេ។ ប្រសិនបើកុមារមានអារម្មណ៍សុវត្ថិភាព ហើយដឹងថាពួកគេជាកម្មសិទ្ធិរបស់ក្រុមគ្រួសារ សហគមន៍ និងវប្បធម៌ ពួកគេអាចមានទំនុកចិត្តក្នុងវិធីដែលពួកគេរៀនសូត្រ។

សួករំកមាប់ព័ត៌មានបដែដ  ្មអ្តំពី Early Years Learning Framework សូមចូល្តវ៉ាមីល៖

https://www.education.gov.au/collections/translations-belonging-being-and-becoming-early-years-learning-framework-australia

### សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកមត្តេយ្យសាលា ឬសេវាកម្មសម្រាប់កុមារតូចរបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រតិបត្តិករនឹងហៅលេខទូរស័ព្ទដែលអ្នកផ្តល់ឱ្យ ហើយរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នក ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

# ការរៀនសូត្រនៅសាលារៀន

## ការរៀនសូត្រសម្រាប់កុមារតូច

កុមារដឹងថាពួកគេជាកម្មសិទ្ធិក្នុងក្រុមគ្រួសារ សហគមន៍ និងវប្បធម៌របស់ពួកគេ

### ការដឹងអំពីអត្តសញ្ញាណច្បាស់លាស់មានន័យថា៖

កុមារដឹងថាពួកគេនឹងមិនអីទេ ហើយអាចគ្រប់គ្រងការផ្លាស់ប្តូរ និងអារម្មណ៍

កុមារដឹងថាអ្វីដែលជាឥទ្ធិពលរបស់ពួកគេមានលើមនុស្ស ទីកន្លែង និងការរៀនសូត្ររបស់ពួកគេផ្ទាល់

កុមារដឹងពីរបៀបចែករំលែក រៀនពី គោរព និងនៅជាមួយអ្នកដទៃ

សិស្សទំនាក់ទំនង និងប្រាស្រ័យទាក់ទងជាមួយក្រុមវប្បធម៌ផ្សេងៗ (ផ្នែកមុខវិជ្ជាទាំងអស់)

សិស្សដឹងពីឥរិយាបថសីលធម៌ ហើយអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន និងសង្គម (ផ្នែកមុខវិជ្ជាទាំងអស់)

សិស្សមានទំនុកចិត្តក្នុងការគាំទ្រសុខភាព និងសុខុមាលភាពរបស់ពួកគេ (មុខវិជ្ជា៖ ការអប់រំរាងកាយ)

សិស្សអាចស្វែងយល់ គោរព និងអបអរសាទរវប្បធម៌ដទៃទៀត (ផ្នែកមុខវិជ្ជាទាំងអស់)